# នាម និង រូប

ដកស្រង់ពីគម្ពីពុទ្ធសាសនាអនាមិកមួយជាភាសាបាលីស្តីពីការពីការសារសង រវាង ព្រះចៅមីលិនដាបញ្ញានៅប្រទេសឥណ្ឌា ជាមួយនឹង ភិក្ខុនាគសេនា (សរសេរប្រហែលនៅសតវត្សទី ១៦៣ ទៅ ៩៥ មុនគ.ស.)។

កម្ពីនេះ បានបកប្រែបែបបីយ៉ាងជាភាសាចិនប្រហែលនៅសតវត្សទី៣១៧ ទៅ ៤២០ ក.ស.គ. មានចំណងជើងថា « សៀវភៅ នៃភិក្ខុនាគសេនា »។ លោក Louis FINOT បកប្រែជាភាសាបារាំង ពី ភាសាបាលី ចុះផ្សាយពីអ្នកបោះពុម្ពផ្សាយ GUILLIMARD នៅឆ្នាំ១៩៩២។

- ព្រះចៅ មីលិនដា សួរទៅភិក្ខុ នាគសេនាថា : ព្រះភិក្ខុ ព្រះអង្គមានពុទ្ធដីកាអំពី នាម និង រូប។ តើអ្វីជានាម ? តើអ្វីជារូប ?
- ពិក្ខុនាគសេនា : អ្វីជា សម្ភារៈ គឺជា រូប ; អ្វីជា ភារៈបញ្ញា និងខាងវិញ្ញាណ គឺជានាម។
- ព្រះចៅ មីលិនដា : តើហេតុអ្វីបានជា នាម និង រូប មិនអាចកើតឡើងវិញដោយឯកោ ?
- ពិក្ខុនាគសេនា : ពីព្រោះ នាម និង រូប វាពឹងផ្អែកលើគ្នាទៅវិញទៅមក។
- ព្រះចៅ មីលិនដា : សូមព្រះភិក្ខុ ធ្វើការប្រៀបធៀបអោយករុណាបានដឹងផង។
- ពិក្ខុនាគសេនា : ជាឧទាហរណ៍ មាន់ញី បើនៅក្នុងខ្លួនវា គ្មានជីវល្លូ វាមិនអាចបង្កបង្កើតជាស៊ុតបានឡើយ ; ជីវល្លូ និង ស៊ុត វាមានលក្ខណៈចងព័ន្ធគ្នាទៅវិញទៅមក ; កំណើតរបស់វា វាព្រមគ្នា។ ដូចគ្នានេះដែរ បើគ្មាននាម ក៏វាគ្មានរូបនោះដែរ ; នាម និង រូប វាមានលក្ខណៈចងព័ន្ធគ្នាទៅវិញទៅមក ; កំណើតរបស់វា វាព្រមគ្នា។ ដូច្នេះ បានជាវាកើតឡើងព្រមគ្នាក្នុងរយៈពេលមិនកំណត់មួយ។